CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបើកបន្ថែមកន្លែងធ្វើតេស្តរកជំងឺកូវីដ-១៩នៅស្តាត Veterans Memorial

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – ជំរើសនៃការធ្វើតេស្តរកជំងឺកូវីដ-១៩នៅតែបន្តកើនឡើងនៅឡុងប៊ិចដោយការបើកដំណើរការទីតាំងមួយទៀតនៅថ្ងៃនេះ ១ ខែឧសភានៅស្តាត Veterans Memorial តាមរយៈការចាប់ដៃគូជាមួយមហាវិទ្យាល័យនៃទីក្រុងឡុងប៊ិច។

អភិបាលក្រុងលោក Robert Garcia បានមានប្រសាសន៍ថា "ការដែលមានសមត្ថភាពមាំក្នុងការធ្វើតេស្តគឺមានសារៈសំខាន់ណាស់ក្នុងការការពារសុវត្ថិភាពរបស់ប្រជាជននិងបើកដំណើរការសេដ្ឋកិច្ចរបស់ឡុងប៊ិចឡើងវិញជាបណ្តើរៗ។ ខ្ញុំសូមថ្លែងអំណរគុណដល់មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិចដែលបានចាប់ដៃគូជាមួយគ្នា។"

ទីតាំងធ្វើតេស្តតាមរថយន្តថ្មីត្រូវបានរំពឹងថានឹងផ្តល់តេស្ត ១០០ ក្នុងមួយថ្ងៃ។ ដោយមានទីតាំងថ្មីនេះទីក្រុងឡុងប៊ិចមានសមត្ថភាពធ្វើតេស្តមនុស្សជាង ៧០០ នាក់ក្នុងមួយថ្ងៃបន្ថែមពីលើបុគ្គល ២៥០ នាក់ទៀតដែលអាចធ្វើតេស្តនៅមន្ទីរពេទ្យ St. Mary ដូច្នេះបង្កើនសមត្ថភាពធ្វើតេស្តិ៍ប្រចាំថ្ងៃសរុបដល់ប្រមាណ ១០០០ នាក់។

ស្តាត Veterans Memorial ដែលមានទីតាំងនៅ 5000 E. Lew Davis St. បើក ៧ ថ្ងៃក្នុងមួយសប្តាហ៍ចាប់ពីម៉ោង ៣ រសៀលដល់ម៉ោង ៦ ល្ងាច។

ការធ្វើតេស្តតម្រូវឱ្យមានការណាត់ជួបជាមុនហើយការណាត់ជួបគឺអាចកំណត់បានដោយចូលទៅកាន់គេហទំព័រធ្វើតេស្តកូវីដ-១៩នៃទីក្រុងឬដោយទូរស័ព្ទទៅលេខ 562.570.INFO (4636)។ ការណាត់ជួបនឹងត្រូវបានផ្តល់អាទិភាពដល់អ្នកដែលមានរោគសញ្ញា បុគ្គលដែលមានអាយុលើសពី៦៥ឆ្នាំ ឬមានសុខភាពរ៉ាំរ៉ៃ និងអ្នកធ្វើការជួរមុខសំខាន់ៗ។

ការណាត់ជួបធ្វើតេស្តនៅតែបន្តសម្រាប់អ្នកដែលមានរោគសញ្ញានៅឯទីតាំងធ្វើតេស្តចំនួន ៥ ផ្សេងទៀតក្នុងទីក្រុងឡុងប៊ិច៖

- សាលារៀន Jordan High School, 6500 Atlantic Ave.
- សាលារៀន Cabrillo High School, 2001 Santa Fe Ave.
- មន្ទីរពេទ្យសាំងម៉ារី (St. Mary Medical Center), 1050 Linden Ave.
- មហាវិទ្យាល័យនៃទីក្រុងឡុងប៊ិចសាខាឆ្នេរប៉ាស៊ីហ្វិក (Pacific Coast Campus*), 1305 E. Pacific Coast Highway
- ចាប់ពីថ្ងៃទី ៤ ខែឧសភា៖ សាលារៀន Jordan Plus High School, 171 W. Bort St.

សម្រាប់ព័ត៌មានថ្មីៗអំពីកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###